# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតចំហ
## សូមគោរពជូន USAID ប្រចាំកម្ពុជា

យើងខ្ញុំទាំងអស់គ្នាជាសមាជិកបណ្តាញសហគមន៍ព្រៃឡង់ (PLCN) បានធ្វើកិច្ចការការពារព្រៃឡង់អស់ជាងពីទសវត្សរ៍។ យើងខ្ញុំបានចងក្រងជាបណ្តាញមកពីខេត្តចំនួនបួន មានជាង ១០០ភូមិ ដែលបានទទួលស្គាល់ និងរីករាយចំពោះគុណសម្បត្តិដ៏ល្អរបស់ព្រៃឡង់ និងការការពារព្រៃមួយនេះ។ យើងបានខិតខំធ្វើការដោយមិនខ្លាចនឿយហត់ ដើម្បីការពារព្រៃឡង់ ពីការកាប់បំផ្លាញខុសច្បាប់ ការបរបាញ់ សម្បទានដី និងការជីកយករ៉ែផ្សេងៗ។ ការខិតខំប្រឹងប្រែងរបស់យើងខ្ញុំទាំងនេះ ក្នុងនាមជាអ្នកស្ម័គ្រចិត្ត ដែលតែងតែលះបង់ពេលវេលាដ៏មានតម្លៃរបស់យើង ដើម្បីល្បាតការពារព្រៃឡង់។

យើងខ្ញុំនឿយហត់ និងអស់កម្លាំង នៅគ្រប់ពេលដែលយើងខ្ញុំបានចំណាយពេលធ្វើការងារទាំងយប់ព្រលប់នៅក្នុងព្រៃ ហើយពេលខ្លះ ម៉ូតូរបស់យើងខ្ញុំត្រូវបានខូចខាតដែលមិនអាចជួសជុលបានជាច្រើនដងរាប់មិនអស់នៅក្នុងព្រៃឡង់ ក្នុងបុព្វហេតុការពារព្រៃឈើ។ ហើយអ្វីដែលគួរឱ្យនឿយហត់ និងខ្វល់ខ្វាយជាងនេះទៅទៀត គឺការប្រឈមមុខនឹងការគំរាមកំហែងដោយហិង្សា និងការចាប់ខ្លួនពីអ្នកកាប់ឈើខុសច្បាប់ ហើយយើងស្រមៃថា នឹងមិនអាចមកជួបមុខក្រុមគ្រួសាររបស់យើងម្តងទៀត និងការគំរាមកំហែងដោយហិង្សា និងការចាប់ខ្លួនពីសំណាក់អាជ្ញាធរ។ យើងបានឆ្លងកាត់គ្រោះថ្នាក់ ការវាយប្រហារ និងការបាត់បង់ជីវិត។ អ្នកនាំពាក្យរបស់ដៃគូ USAID គឺក្រសួងបរិស្ថាន (MoE) បានគំរាមចាប់ខ្លួនជាសាធារណៈដល់សមាជិកបណ្តាញ ប្រសិនបើយើងខ្ញុំនៅបន្ត ប្រើរូបភាពផ្កាយរណប ដើម្បីតាមដានការកាប់បំផ្លាញព្រៃឈើនៅតំបន់ព្រៃឡង់។ បញ្ហាប្រឈមទាំងនេះហើយខ្ញុំសង្កេតឃើញថា USAID មិនដែលគាំទ្រ ឬការពារសិទ្ធិរបស់យើងខ្ញុំឡើយ។

យើងខ្ញុំជាបណ្តាញសហគមន៍ព្រៃឡង់ មានការខកចិត្តជាខ្លាំង នៅពេលដែលបានឃើញសេចក្តីថ្លែងការណ៍ថ្មីៗនេះរបស់ USAID អះអាងថា "បានធ្វើការផ្ទាល់ជាមួយ បណ្តាញសហគមន៍ព្រៃឡង់" ។ យើងខ្ញុំមិនដែលឃើញ USAID ធ្វើការផ្ទាល់ជាមួយយើងខ្ញុំម្តងណាឡើយ។ USAID មិនដែលផ្តល់ដំណឹងអំពីគម្រោងព្រៃឡង់បៃតង របស់ខ្លួនដល់យើងខ្ញុំនោះទេ។ USAID មិនដែលបានសួរយើងខ្ញុំថា តើយើងខ្ញុំយល់ព្រម នឹងអ្វីដែល USAID កំពុងធ្វើនៅលើព្រៃដូនតារបស់យើងឡើយ។ ហើយយើងខ្ញុំមិនដែលទទួលបានជំនួយផ្នែកហិរញ្ញវត្ថុ ឬបច្ចេកទេសពី USAID ផងដែរ។

ផ្ទុយទៅវិញ យើងខ្ញុំបានស្នើសុំជួបប្រជុំជាមួយ USAID ជាច្រើនដង ប៉ុន្តែការប្រជុំភាគច្រើន តែងតែពន្យារពេល ឬលុបចោលនៅក្នុងហេតុផលផ្សេងៗ។ កិច្ចប្រជុំដែលត្រូវបានអញ្ជើញដោយ USAID គឺកំណត់ត្រឹមជាលក្ខណៈបុគ្គលរបស់បណ្តាញ ១នាក់ ឬ២នាក់ ក្រោមហេតុផលថា ការិយាល័យរបស់ USAID មិនមានទំហំធំគ្រប់គ្រាន់ ដើម្បីអញ្ជើញតំណាងបណ្តាញមកពីខេត្តចំនួន៤ឡើយ។ នេះមិនមែនជារបៀបដែលយើងខ្ញុំធ្វើការនោះទេ។ យើងខ្ញុំធ្វើការងារជាបណ្តាញ ហើយមិនមែនជាបុគ្គលដែលអ្នកអាចទិញដូរ ឬបំភិតបំភ័យបានឡើយ។

បណ្តាញសហគមន៍ព្រៃឡង់បានស្នើសុំ ដើម្បីទទួលបានការអញ្ជើញជាភាគីពាក់ព័ន្ធ នៅក្នុងគម្រោងរបស់ USAID នៅតំបន់ព្រៃឡង់ជាច្រើនដង ប៉ុន្តែសំណើរបស់យើងខ្ញុំ ដើម្បីទទួលបានការអញ្ជើញឱ្យចូលរួមគម្រោងដ៏ធំរបស់ USAID លើការ "គាំទ្រដល់ជីវចម្រុះព្រៃឈើ" និង "ព្រៃឡង់បៃតង" តែងតែត្រូវបានបដិសេធដោយ USAID ។

អ្វីដែលអះអាងថាUSAID គាំទ្របណ្តាញសហគមន៍ព្រៃឡង់ ដើម្បីល្បាតរួមគ្នាជាមួយក្រសួងបរិស្ថាន វាជាការអះអាងដែលមិនមានការពិត។ USAID បានចំណាយប្រាក់ឱ្យអតីតសមាជិកបណ្តាញសហគមន៍ព្រៃឡង់ ដើម្បីធ្វើការជាមួយក្រសួងបរិស្ថាន ជាសហគមន៍តំបន់ការពារ (CPAs)។ តំបន់ការពារទាំងនេះ មានទំហំតូច និងមានតម្លៃផ្នែកជីវចម្រុះនិងភាពរឹងមាំព្រៃឈើតិចតួច។ យើងខ្ញុំធ្លាប់ត្រូវបានណែនាំឱ្យបំបែកខ្លួនទៅជាសហគមន៍តំបន់ការពារ ដើម្បីល្បាតនៅតំបន់ការពារនោះ ហើយក្រសួងបរិស្ថាន បង្ខំឱ្យសន្យាថា នឹងមិនដើរល្បាតនៅតំបន់ព្រៃឡង់ទៀតឡើយ។ នេះគឺជាយុទ្ធសាស្ត្ររបស់ក្រសួងបរិស្ថានក្នុងការបញ្ឈប់ការចងក្រងឯកសារ នៃការកាប់ឈើខុសច្បាប់នៅតំបន់ព្រៃឡង់ ដែលការបង្ខំឱ្យយើងទទួលយករបៀបធ្វើការបែបនេះ គឺវាមិនអាចទៅរួចសម្រាប់បណ្តាញសហគមន៍ព្រៃឡង់នោះទេ។

សំណួររបស់យើងខ្ញុំចំពោះ USAID គឺ៖ ហេតុអ្វីបានជា USAID អះអាងថា បានធ្វើការផ្ទាល់ជាមួយបណ្តាញសហគមន៍ព្រៃឡង់?

ប្រសិនបើ USAID មិនចង់ធ្វើការជាមួយប្រជាជនមូលដ្ឋាន និងជនជាតិដើមភាគតិចទេ នោះគឺជាការសម្រេចចិត្តរបស់ USAID ប៉ុន្តែសូមគោរពយើងខ្ញុំជាបណ្តាញ ហើយមិនត្រូវប្រើឈ្មោះរបស់យើងខ្ញុំ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនឡើយ។ សេចក្តីថ្លែងការណ៍របស់USAIDមិនអាចទទួលយកបានឡើយសម្រាប់បណ្តាញសហគមន៍ព្រៃឡង់ ហើយយើងខ្ញុំស្នើសុំឱ្យមានការប្តូរពាក្យនេះចេញ។

ប្រសិនបើ USAID មានបំណងសហការ ឬគាំទ្រ បណ្តាញសហគមន៍ព្រៃឡង់ យើងខ្ញុំរីករាយស្វាគមន៍ ហើយសូមទទួលយកការអញ្ជើញនេះ ដើម្បីមកជួបយើងខ្ញុំនៅតាមខេត្តនីមួយៗ។

ចំពោះយើងខ្ញុំទាំងអស់គ្នា ព្រៃឡង់ គឺជាជីវិត។ យើងខ្ញុំនឹងបន្តឱ្យអស់ពីសមត្ថភាពដើម្បីការពារព្រៃមួយនេះ ហើយយើងខ្ញុំសង្ឃឹមថា USAID នឹងទទួលយកការអញ្ជើញរបស់យើង ដើម្បីមកមើលការងាររបស់យើង ហើយពិភាក្សាពីរបៀបដែលយើងអាចគាំទ្រគ្នាទៅវិញទៅមកបាន។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតំណាងសហគមន៍តាមរយៈលេខទូរស័ព្ទដូចខាងក្រោម៖

១. លោក ឯក សុវណ្ណា ០៩៧ ៦៤៤ ៩៩៩៨

២. លោក ស្វាយ សុង ០៧១ ៤៥១ ៩៤៦៥

៣. លោក ស្រី ចី ០៩៩ ៧២២ ១៨៧

៤. លោក ខេម សុឃី ០៨៥ ៤៧៣ ១៥៧

៥. លោក ម៉ិញ នី ០៩៦ ៣០០ ២៧៦២

៦. លោក ហឿន សុភាព ០១២ ៣៧៣ ៤៤១

៧. កញ្ញា ឈាង លី ០៩៦ ៦៦៨ ០៦៧៣

៨. លោក ខេង ខូ ០៧១ ៤៥១ ៩៤៦៣

**យើងរួមគ្នាការពារព្រៃឡង់ "ព្រៃឡង់ ជាព្រៃរបស់យើងទាំងអស់គ្នា!"**

ធ្វើនៅថ្ងៃចន្ទ ៩កើត ខែចេត្រ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤

ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១